- បានឃើញសំណើរួមរបស់ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងឧស្សាហកម្មរ៉ែ និងថាមពល
- យោងស្មារតីសម័យប្រជុំពេញអង្គរបស់គណៈរដ្ឋមន្ត្រី នាថ្ងៃទី១៩ ខែមករា ឆ្នាំ១៩៩៩

**សំរេច**

**ប្រការ ១ :** កំណត់តំលៃជាវចរន្តអគ្គិសនី នៅក្រុងព្រះសីហនុ សំរាប់អតិថិជនទាំងអស់ទៅតាមប្រភេទ និងថ្លៃដូចខាងក្រោម :

១-អតិថិជន លំនៅដ្ឋាន : តំលៃលក់ ៥០០រៀល ក្នុង០១គីឡូវ៉ាត់ម៉ោង ត្រូវបានរក្សាទុកដដែល។

២-អតិថិជនឧស្សាហកម្ម និងសិប្បកម្ម : តំលៃលក់ ១៧,៥០ សេនដុល្លារអាមេរិក ក្នុង០១ គីឡូវ៉ាត់ ម៉ោង ។

៣-អតិថិជន ពាណិជ្ជកម្ម អាជីវកម្ម និងសេវាកម្មផ្សេងៗ : តំលៃលក់ ១៩,៥០ សេនដុល្លារអាមេរិក ក្នុង ០១ គីឡូវ៉ាត់ម៉ោង ។

៤-អតិថិជនស្ថានទូត សណ្ឋាគារ ផ្ទះជួលអោយជនបរទេស : តំលៃលក់ ២០ សេនដុល្លារអាមេរិក ក្នុង ០១គីឡូវ៉ាត់ម៉ោង ។

៥-អតិថិនជន អង្គភាពរដ្ឋបាលបុព្វហេតុ : តំលៃលក់ ២០ សេនដុល្លារអាមេរិក ក្នុង ០១ គីឡូវ៉ាត់ ម៉ោង ។

**ប្រការ ២ :** សេចក្តីសំរេចរបស់រាជរដ្ឋាភិបាល ស្តីពីការកំណត់ថ្លៃជាវអគ្គិសនីពីមុន និងបទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីសេចក្តីសំរេចនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៣ :** ទេសរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្មរ៉ែ និងថាមពល រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃក្រសួង - ស្ថាប័នពាក់ព័ន្ធ អភិបាលក្រុងព្រះសីហនុ និងអគ្គិសនីកម្ពុជាមានភារកិច្ចអនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាពចាប់ពី ថ្ងៃទី ០១ ខែ មីនា ឆ្នាំ ១៩៩៩ តទៅ ។

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

★★★

## សេចក្តីសំរេចលេខ ១៥ សសរ

រាជធានីភ្នំពេញ,ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ១៩៩៩

### ស្តីពីការផ្ទេរភារកិច្ច នៃរាជរដ្ឋាភិបាល

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមសំណូមពរការងារចាំបាច់របស់រាជរដ្ឋាភិបាល

**សំរេច**

ប្រការ ១ : ផ្ទេរសិទ្ធិជូនឯកឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រី និង ជាសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជានាយករដ្ឋមន្ត្រីស្តីទី នៃរាជរដ្ឋាភិបាល ជំនួសសម្តេចនាយករដ្ឋមន្ត្រី ដែលត្រូវអញ្ជើញទៅបំពេញទស្សនកិច្ចនិងចូលរួមប្រជុំពិគ្រោះយោបល់ស្តីពីកម្ពុជា នៃបណ្តាប្រទេសផ្តល់ជំនួយ នៅទីក្រុងតូក្យូ ប្រទេសជប៉ុន ចាប់ពីថ្ងៃទី២៣ ខែ កុម្ភៈ ឆ្នាំ១៩៩៩ រហូតដល់សម្តេចនាយករដ្ឋមន្ត្រីអញ្ជើញវិលនិវត្តន៍មកកាន់មាតុប្រទេសវិញ ។

ប្រការ ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ខេត្ត-ក្រុង និងឯកឧត្តម ស ខេង ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

★★★

## សេចក្តីសំរេចលេខ ១៦ សសរ

រាជធានីភ្នំពេញ,ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ១៩៩៩

### ស្តីពីការបង្កើតគណៈកម្មការគ្រប់គ្រងផ្នែកនាំចេញនៃកម្មសិទ្ធិបញ្ញា

***

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- យោងកិច្ចព្រមព្រៀង ស្តីពីទំនាក់ទំនងពាណិជ្ជកម្ម និង កម្មសិទ្ធិបញ្ញា រវាងព្រះរាជាណាចក្រកម្ពុជា និងសហរដ្ឋអាមេរិក ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ១៩៩៦
- យោងតាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម